Australian Government

NATIONAL CERVICAL SCREENING PROGRAM
A joint Australian, State and Territory Government Program

# ការធ្វើតេស្តពិនិត្យមាត់ស្បូន៖ របៀបយកសំណាកផ្ទាល់ខ្លួនរបស់អ្នក

ក្រដាសណែនាំនេះ នឹងជួយអ្នកក្នុងការប្រមូលសំណាកយោនីផ្ទាល់ខ្លួនរបស់អ្នកសម្រាប់ការពិនិត្យមាត់ស្បូន។ ប្រសិនបើអ្នកមិនប្រាកដអំពីអ្វីមួយ ឬមានសំណួរណាមួយ អ្នកអាចនិយាយទៅកាន់អ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នកបាន។




## 1. មុនពេលចាប់ផ្តើម

- អ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នក នឹងផ្តល់ឱ្យអ្នកនូវកន្លែងឯកជនមួយ ដើម្បីប្រមូលសំណាករបស់អ្នក។ នេះអាចជាកន្លែងមួយនៅពីក្រោយរបាំង ឬក្នុងបន្ទប់ទឹក។ បន្ទាប់មក អ្នកនឹងទទួលបានកញ្ចប់មួយ។ នៅខាងក្នុងគឺជាតម្បារចុងសំឡីមួយ។ តម្បារចុងសំឡីរបស់អ្នក អាចមើលទៅខុសគ្នាទៅនឹងរូបភាពនៅទីនេះ។
- មុនពេលអ្នកបើកកញ្ចប់ សូមប្រាកដថាអ្នកដឹងថាត្រូវកាន់ចុងតម្បារសំឡីមួយណា (ចុង Tip A) ហើយថាចុងមួយណាសម្រាប់យកសំណាក (ចុង Tip B)។ ប្រសិនបើអ្នកមិនប្រាកដថាចុងមួយណាសម្រាប់កាន់ ឬសម្រាប់យកសំណាកនោះ សូមស្នើសុំឱវាទពីអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នក។
- ត្រូវប្រាកដថាដៃរបស់អ្នកស្អាត ហើយស្ងួត រៀបចំខ្លួនអ្នកនៅក្នុងទីតាំងដែលមានផាសុកភាព ហើយសម្រាតចុះខោស្លីបរបស់អ្នក។




## 2. ការរៀបចំតម្បារចុងសំឡី

- មួលបើកគម្រប ហើយយកតម្បារចុងសំឡីចេញពីកញ្ចប់។
- ត្រូវប្រាកដថាកុំប៉ះចុង Tip B ដែលនឹងត្រូវស៊កបញ្ចូលដើម្បីប្រមូលសំណាក។
- កុំដាក់សំណាកចុះ។







## 3. ការស៊កបញ្ចូលតម្បារចុងសំឡី

- ប្រើដៃទំនេរម្ខាងទៀតរបស់អ្នក ដើម្បីបើកផ្នត់ស្បែកនៅច្រកចូលយោនីរបស់អ្នក។
- ស៊កបញ្ចូលចុង Tip B ដោយថ្នមៗទៅក្នុងយោនីរបស់អ្នកក្នុងជម្រៅពីរបីសង់ទីម៉ែត្រ។
- តម្បារចុងសំឡីអាចមានបន្ទាត់ ឬគំនូសសម្គាល់នៅលើវាដែលបង្ហាញអ្នកពីជម្រៅដើម្បីស៊កបញ្ចូល។

## 4. ការយកសំណាក

- បង្វិលតម្បារចុងសំឡីដោយថ្នមៗរយៈពេល 10-30 វិនាទី (ក្នុងទិសដៅណាមួយក៏បាន)។







## 5. ការរក្សាទុកសំណាក

- នៅកាន់ចុង Tip A ដដែល ដកយកតម្បារចុងសំឡីចេញពីយោនីរបស់អ្នកដោយថ្នមៗ។
- ដាក់តម្បារចុងសំឡីចូលទៅក្នុងកញ្ចប់វិញ ដោយដាក់ចុង Tip B ចូលជាមុន។
- មួលបិទគម្របទៅវិញ។ ស្លៀកពាក់វិញ ហើយប្រគល់កញ្ចប់ទៅអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នកវិញ។

## 6. ការផ្ញើសំណាក

- គេនឹងបញ្ជូនសំណាកទៅមន្ទីរពិសោធន៍រោគវិទ្យា ដើម្បីធ្វើតេស្តរកមើលវីរុស HPV។
- លទ្ធផលនៃការធ្វើតេស្តនឹងត្រូវគេផ្ញើទៅអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នក។

## ចុះប្រសិនបើ...?

| | |
|---|---|
| ចុះប្រសិនបើខ្ញុំបានប៉ះចុង **Tip B**/តម្បារចុងសំឡី ជាមួយម្រាមដៃរបស់ខ្ញុំដោយច្រឡំ? | សូមបន្តយកសំណាក។ |
| ចុះប្រសិនបើខ្ញុំបានទម្លាក់ចុង **Tip B**/តម្បារចុងសំឡីទៅលើផ្ទៃស្ងួត? | សូមបន្តយកសំណាក។ |
| ចុះប្រសិនបើខ្ញុំបានទម្លាក់ចុង **Tip B**/តម្បារចុងសំឡីទៅលើផ្ទៃសើម? | ប្រាប់អ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នកឱ្យបានដឹង ហើយស្នើសុំតម្បារចុងសំឡីថ្មីមួយទៀត។ |

**ប្រសិនបើមានការរកឃើញវីរុស HPV អ្នកនឹងត្រូវត្រឡប់ទៅជួបអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នក ដើម្បីឱ្យពួកគេប្រមូលសំណាកពីមាត់ស្បូនរបស់អ្នក ឬអ្នកអាចត្រូវគេបញ្ជូនបន្តទៅជួបគ្រូពេទ្យឯកទេសម្នាក់ដើម្បីធ្វើតេស្តបន្ថែម។**

ក្រដាសណែនាំនេះគឺសម្រាប់គោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ។ វាអាចមានភាពខុសប្លែកគ្នាខ្លះរវាងប្រភេទនៃតម្បារចុងសំឡីប្រមូលដោយខ្លួនឯង ដែលបានបង្ហាញនៅក្នុងក្រដាសណែនាំនេះ ជាមួយនឹងតម្បារចុងសំឡីដែលប្រើដោយអ្នកផ្តល់សេវាកម្មថែទាំសុខភាព ឬមន្ទីរពិសោធន៍របស់អ្នក។
សូមនិយាយជាមួយអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់អ្នក ប្រសិនបើអ្នកមានសំណួរណាមួយទាក់ទងនឹងដំណើរការប្រមូលសំណាកដោយខ្លួនឯង។